ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៨ លេខ ០៨

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC



ក ស វ

**Work Activities**

ប្រចាំខែសីហា ឆ្នាំ២០១៥



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពីទិវាជាតិអំណាន | ១ |
| ២- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | ២ |
| ៣- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែកក្កដា ឆ្នាំ២០១៥ | ៤ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១២ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ទិវាជាតិអំណាន

កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ជីវ សុខហាក់** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីទិវាជាតិអំណាន** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក និងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងអប់រំ យុវជន និងកីឡា។



អនុវត្តតាមគោលនយោបាយកំណែទម្រង់វិស័យអប់រំសំដៅឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំច្បាប់ស្តីពីការអប់រំដែលត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧។ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការកសាងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីការអប់រំឲ្យមានប្រសិទ្ធភាពដែលក្នុងនោះក៏មានអនុក្រឹត្យស្តីពីទិវាជាតិអំណាននេះផងដែរ។

ការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីទិវាជាតិអំណាន មានគោលបំណងបណ្តុះទម្លាប់អាន ជំរុញវប្បធម៌អាន លើកកម្ពស់សមត្ថភាពអាន និងការតែងនិពន្ធ រួមចំណែកការពារ និងពង្រឹងវប្បធម៌ អរិយធម៌ខ្មែរ។

សេចក្តីព្រាងអនុក្រឹត្យស្តីពីទិវាជាតិអំណាន ត្រូវបានរៀបចំឡើងដោយ ក្រសួងអប់រំ យុវជន និងកីឡា តាំងពីឆ្នាំ២០០៩ ហើយបានប្រជុំពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធជាច្រើនលើកច្រើនសារ[១]។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុរបស់សេចក្តីព្រាងអនុក្រឹត្យស្តីពីទិវាជាតិអំណាន។

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៥ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឌុយ ឆៅ** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **សុក ផេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍ វិស័យកសិកម្ម និងជនបទ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងអគ្គលេខាធិការ ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ។



នៅក្នុងឆ្នាំ២០០៨ ដោយមានការប្រគល់ភារកិច្ចជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** រាជរដ្ឋាភិបាលកម្ពុជា ក៏បានរៀបចំព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៦៦ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដែលមានសមាសភាពឥស្សរៈជនជាន់ខ្ពស់មួយរូបជាប្រធាន ឥស្សរៈជនមួយឬច្រើនរូបជាអនុប្រធាន និងមានរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការនៃក្រសួង ស្ថាប័នមួយចំនួនជាសមាជិក។ ដោយមើលឃើញពីភាពចាំបាច់នៃការវិវត្តការងារថ្មីៗ ក៏ដូចជាអាណត្តិការងារមួយចំនួនដែលរាជរដ្ឋាភិបាលកម្ពុជាប្រគល់ជូនក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្នុងតួនាទីជាអ្នកសម្របសម្រួលលើបញ្ហាអន្តរវិស័យនានា ជាពិសេសកិច្ចសម្របសម្រួលការងារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ ការងារសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ការងារគាំពារសង្គម និងកិច្ចការបន្ថែមថ្មីៗទៀត ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ(ក.ក.ជ.)បានធ្វើការកែសម្រួលសមាសភាព រចនាសម្ព័ន្ធ តួនាទី និង

និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាននៃក.ក.ជ. និងធ្វើការកែសម្រួលឈ្មោះនាយកដ្ឋានមួយចំនួន ដើម្បីឲ្យស្របទៅនឹងតម្រូវការជាក់ស្តែងនៅកម្ពុជា ក៏ដូចជាបញ្ចៀសនូវការជាន់គ្រួតគ្នានៃតួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័ន ជាពិសេស ដើម្បីពង្រឹងឲ្យទៅជាគណៈបញ្ជាការឯកភាពមួយដែលជាសេនាធិការ ជូនរាជរដ្ឋាភិបាល ទទួលខុសត្រូវលើការងារដឹកនាំសម្របសម្រួល ពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រជាតិពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ ការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភនិងការគាំពារសង្គម ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។

ម្យ៉ាងទៀត យោងតាមមាត្រា១៧ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៦៦ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ចែងថា "ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ ក.ក.ជ. ត្រូវកំណត់ដោយអនុក្រឹត្យ" ក៏ប៉ុន្តែដោយហេតុថា កន្លងមកពុំទាន់មានអនុក្រឹត្យដាច់ដោយឡែកដែលចែងអំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក.ក.ជ. ទើបតម្រូវឲ្យមានការរៀបចំអនុក្រឹត្យនេះ ដើម្បីឲ្យស្របទៅនឹងទម្រង់ច្បាប់ និងការកំណត់តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ ឲ្យបានច្បាស់លាស់[១]។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។



(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុរបស់សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកក្កដា ឆ្នាំ២០១៥*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌កម្ពុជា **ប្រចាំខែកក្កដា ឆ្នាំ២០១៥**នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (ECOSOCC) នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ដឹកនាំដោយ ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែកក្កដាឆ្នាំ២០១៥សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,៦% ធៀបនឹងខែមុន និងកើនឡើង០,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| ក្រុមទំនិញ: | | មុខទំនិញ: | |
|---|---|---|---|
| ភោជនីយដ្ឋាន: | +៤,៣% | បន្លែ: | +៨,៣% |
| សំលៀកបំពាក់ និងស្បែកជើង: | +៣,៦% | ត្រីស្រស់: | +៨,០% |
| ម្ហូបអាហារ: | +៣,៥% | អង្ករ: | +២,៥% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: | +២,៥% | សាច់គោ: | +១,៨% |
| ការកម្សាន្ត និងវប្បធម៌: | +១,៩% | សាច់ជ្រូក: | +១,២% |
| | | ផ្លែឈើ: | +១,២% |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៣–២០១៥

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា[P] | កញ្ញា[P] | តុលា[P] | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៥ | ដូចគ្នាឆ្នាំមុន | ០,៤% | ១,៦% | ១,១% | ១,៣% | ១,០% | ០,៧% | ០,៨% | ០,៨% | ០.៩% | ០.៩% | | | |
| | មុន | -០,៤% | ១,២% | ០,១% | ០,៧% | ០,១% | ០,២% | ០,៦% | ០,៣% | ០,៣% | -០,៤% | | | |
| ២០១៤ | ដូចគ្នាឆ្នាំមុន | ៤,៥% | ៤,៣% | ៥,០% | ៤,៩% | ៤,៦% | ៤,៩% | ៤,២% | ៤,១% | ៣,៦% | ២,៩% | ២,៤% | ២,៥% | ៤,០% |
| | មុន | ០,២% | ០ | ០,៥% | ០,៥% | ០,៣% | ០,៥% | ០,៤% | ០,៣% | ០,២% | -០,៤% | -០,៨% | ០,៧% | |
| ២០១៣ | ដូចគ្នាឆ្នាំមុន | ១,៨% | ១,៧% | ១,០% | ១,០% | ២,៨% | ២,៩% | ៤,០% | ៣,៣% | ៣,៩% | ៤,២% | ៤,១% | ៤,៧% | ៣,០% |
| | មុន | ០,៣% | ០,២% | -០,១% | ០,៦% | ០,៧% | ០,២% | ១% | ០,៤% | ០,៧% | ០,២% | -០,៣% | ០,៥% | |

P: តួលេខខែសីហា កញ្ញា និងតុលាឆ្នាំ២០១៥ ជាតួលេខព្យាករ (តាមវិធីសាស្ត្រ DECOMPOSITION)

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់




តារាង១.៣. អត្រាប្តូរប្រាក់

| ប្រភេទ | កក្កដា២០១៥ | មិថុនា២០១៥ | កក្កដា២០១៤ | ប្រភេទ | កក្កដា២០១៥ | មិថុនា២០១៥ | កក្កដា២០១៤ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤១១៣៛/$ | ៤០៩៨៛/$ | ៤០៥០៛/$ | **បាត/ដុល្លារ** | ៣៥,០៨បាត/$ | ៣៣,៧៦បាត/$ | ៣១,៩៤បាត/$ |
| **៛/បាត** | ១១៧៛/បាត | ១២១៛/បាត | ១២៧៛/បាត | **ដុង/ដុល្លារ** | ២១៨១១ដុង/$ | ២១៨១៥ដុង/$ | ២១២២០ដុង/$ |
| **៛/ដុង** | ០,១៨៩៛/ដុង | ០,១៨៨៛/ដុង | ០,១៩១៛/ដុង | | | | |



## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិអគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែកក្កដាឆ្នាំ ២០១៥ថវិកាជាតិមានស្ថានភាពដូចខាងក្រោមៈ

**២.១. ចំណូលថវិកាជាតិ** ៖ អនុវត្តបាន១០៩២,៨ពាន់លានរៀល( *មធ្យមប្រចាំខែ ១០៥% នៃផែនការ*) ក្នុងនោះចំណូលចរន្ត១០២១,៧ពាន់លានរៀល( *មធ្យមប្រចាំខែ ១០២% នៃផែនការ*) និងចំណូលមូលធន៧១,១ពាន់លានរៀល( តួលេខរតនាគារជាតិ )។

➢បើធៀបនឹងខែមុនចំណូលថវិកាជាតិកើនឡើង១២,៦% និងកើនឡើង១៨,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន៩០១,៧ ពាន់លានរៀល កើនឡើង២,២% ធៀបនឹងខែមុននិងកើនឡើង១៣,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន (តាមតួលេខ រតនាគារជាតិ)។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៣-២០១៥ (ពាន់លានរៀល)




✓ចំណូលមិនមែនសារពើពន្ធមានចំនួន ១១៩,៩ពាន់លានរៀល ថយចុះ៤,៨%ធៀបនឹងខែមុននិងថយចុះ១,៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន( តាមតួលេខ រតនាគារជាតិ )។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ** (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ**( តាមតួលេខ រតនាគារជាតិ ) (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ:+១,១% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+១៧,៦%) | ➢ កាស៊ីណូ : -៧៤% | (+៩,៦%) |
| ➢ ចំណូលពន្ធដារ: +៥,៨% (អគ្គនាយកដ្ឋានពន្ធដារ) | (+៥,៩%) | ➢ អាជ្ញាបណ្ណក្នុងស្រុក : +២៦៦,៩% | (+២៧៨,១%) |
| | | ➢កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ :+៦៩,៤% | (+៩,១% |
| | | ➢ នេសាទ:+៣១០,១% | (១៣១,៩%) |
| | | ➢រុក្ខាប្រមាញ់: | |
| | | ➢សម្បទានរ៉ែ:+៥២៦,២% | (+២៧៤,៧%) |
| | | ➢ អាកាសចរណ៍ស៊ីវិល: -៣៨,១% | (+៣៣,៩%) |
| | | ➢ផលទុននៃសកម្មភាពទេសចរណ៍: -១៨,៩% | (+៣,៤%) |
| | | ➢ប្រៃសណីយ៍ និងទូរគមនាគមន៍:-៨៩% | -៦២,១% |
| | | ➢អាករស្មានទូត( លិខិតឆ្លងដែននិងទិដ្ឋាការ ):+១១៩,៤% | (+៥០,៥%) |

**២.២. ចំណាយថវិកាជាតិ** :អនុវត្តបាន ១០២៨,៧ពាន់លានរៀល( *មធ្យមប្រចាំខែ ៥០% នៃផែនការ*) ក្នុងនោះចំណាយចរន្ត ចំនួន ៨៨០,១ពាន់លានរៀល ( *មធ្យមប្រចាំខែ ៦៨% នៃផែនការ*) និងចំណាយមូលធន១៤៨,៥ពាន់លានរៀល( តួលេខរតនាគារជាតិ )។

➢ចំណាយថវិកាជាតិកើនឡើង៥១,៣% ធៀបនឹងខែមុននិងកើនឡើង១៧,១%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តកើនឡើង៦២,៩% ធៀបនឹងខែមុន និងកើនឡើង២២,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមានអតិរេកចំនួន **៦៤,១**ពាន់លានរៀល (តួលេខរតនាគារជាតិ)។

**ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៣–២០១៥**

(ពាន់លានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែកក្កដាឆ្នាំ២០១៥មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ**M** ₂ មានចំនួន៤៦០១៤ពាន់លានរៀលថយចុះ០,៣%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១៦,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។**ការថយចុះនៃ$M_2$** ក្នុងខែនេះ ជារួម បណ្តាលមកពីការថយចុះនៃប្រាក់បញ្ញើជារូបិយបណ្ណ០,៩%។

➢នាខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៦,៦% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨៣,៤%នៃរូបិយវត្ថុ$M_2$។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែកក្កដាឆ្នាំ២០១៥




*តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៥*

| *ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ* | *មករា* | *កុម្ភៈ* | *មីនា* | *មេសា* | *ឧសភា* | *មិថុនា* | *កក្កដា* | *សីហា* | *កញ្ញា* | *តុលា* | *វិច្ឆិកា* | *ធ្នូ* |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | *១៧,៩%* | *១៨%* | *១៧,៦%* | *១៧,១%* | *១៦,៥%* | *១៦,១%* | *១៦,៦%* | | | | | |
| *ប្រាក់រៀលក្រៅធនាគារ* | *១៣,៦%* | *១៣,៧%* | *១៣,៥%* | *១៣,៣%* | *១២,៦%* | *១២,២%* | *១២,៤%* | | | | | |

➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន ៤៦២២លានដុល្លារ កើនឡើង០,៩%ធៀបនឹងខែមុន និងកើនឡើង១៥,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ១៣៨៩៧ ពាន់លានរៀលកើនឡើង ២%ធៀបនឹងខែមុន និងកើនឡើង៦,៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| ផ្តល់ដោយ | កក្កដា២០១៥ | មិថុនា២០១៥ | កក្កដា២០១៤ |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ពាន់លានរៀល) | ៤៥១៩៤ | ៤៤០៤៨ | ៣៣០៦២ |
| ក្នុងនោះ ជារៀល | | ៥៤៦ | ៤៣៤ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ពាន់លានរៀល) | — | ១០,០៦៤ | ៦៨០៩ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,៧៧% | ៦,៧៦% | ៥,៨៧% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៦,២៣% | ១៦,១៩% | ១៦,១២% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៣៨% | ៤,៣៧% | ៤,២៣% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៥៤% | ១១,៥៣% | ១១,៥១% |

## ៤) ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែកក្កដាឆ្នាំ២០១៥ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន៥២ពាន់តោន កើនឡើង១%ធៀបនឹងខែមុន និងកើនឡើង៤៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**រ៉ែ និងថាមពល**:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៥០២,១GWHមានការថយចុះ១%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង២៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គសនីមានចំនួន៣៤២GWHមានការកើនឡើង៣១៥%ធៀបនឹងខែមុន និងកើនឡើង២១%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម**:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន៥៧២,២លានដុល្លារមានការកើនឡើង៣%ធៀបនឹងខែមុន និងកើនឡើង១៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន —កក្កដា២០១៥ | ចំនួន—មិថុនា២០១៥ | ចំនួន—កក្កដា២០១៤ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ៩ | ១០ | ២៨ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៣៨៣ | ១៣៧៩ | ១២១៦ |
| ▪ ឧស្សាហកម្មធុនតូចនិងសិប្បកម្ម(បើកថ្មី) | | | ៨ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | | | |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ២៦៤,៥ពាន់ម$^2$ថយចុះ៣៣%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១៣០%ធៀបនឹងខែដូចគ្នាឆ្នាំមុន។បើគិតជាសាច់ប្រាក់ស្មើនឹង៩១,៣លានដុល្លារថយចុះ២៤%ធៀបនឹងខែមុនប៉ុន្តែកើនឡើង១៧៧%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម² –កក្កដា២០១៥ | ពាន់ម² –មិថុនា២០១៥ | ពាន់ម² –កក្កដា២០១៤ |
|---|---|---|---|
| ▪ លំនៅឋាន | ៩២,១ | ១០២,៦ | ៤៥,២ |
| ▪ ឧស្សាហកម្ម | ៨៦,៦ | ១៧០,០ | ២៤,១ |
| ▪ទេសចរណ៍ | ៦៩ | ១៩,៩ | ១៥,៧ |
| ▪ពាណិជ្ជកម្ម | ១២,៣ | ៦១,៨ | ១,៤ |
| ▪ផ្សេងៗ | ០,០ | ១,៧ | ២៤,៤ |
| អនុញ្ញាតសរុប | ២៦៤,៥ | ៣៩៤,៣ | ១១៤,៩ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺលំនៅដ្ឋាន ៣៤,៨% ឧស្សាហកម្ម ៣២,៧% និង ទេសចរណ៍ ២៦% នៃផ្ទៃក្រឡាសរុប។

### ➢ការងារ

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់–កក្កដា២០១៥ | នាក់–មិថុនា២០១៥ | នាក់–កក្កដា២០១៤ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ ) | ៦០៤ | ៥៣៣ | ១៨៨៨ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ១១៦៨១ | ៨៣៩៩ | ៩៣៧០ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៩៤៥៧ | ៥៩៩៨ | ៦៧២៩ |
| អ្នកទទួលបានការងារក្រៅប្រទេស | ២២២៤ | ២៤០១ | ២៦៤១ |

### ➢វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | កក្កដា២០១៥ | មិថុនា២០១៥ | កក្កដា២០១៤ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ២៣៦,២ | ១៦០,១ | ២៤១,១ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៧៦,៨ | ០ | ៣២,៧ |
| វិស័យឧស្សាហកម្ម (ក្នុងរង់ក្រចកជាតួលេខ | ៨៩,៧ | ៦៤ | ៥៦,២ |
| នៃតំបន់សេដ្ឋកិច្ចពិសេស) | ១ | ៨,៧ | ៥,២ |
| វិស័យទេសចរណ៍ | ០ | ១៣ | ១២ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៦៩,៧ | ៨៣,១ | ១៤០,២ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ២៣ | ១៥ | ១៨ |
| បង្កើតការងារ (ពាន់នាក់) | ៣០,៦ | ១៨,៩ | ១៨,៨ |

### ➢សេវាកម្ម

តារាង៤.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន –កក្កដា២០១៥ | ចំនួន–មិថុនា២០១៥ | ចំនួន–កក្កដា២០១៤ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៤០៥ | ៤៤៧ | ៤០០ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ១១ | ២ | ១០ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | | ១៦២ | ៤៤០ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន៦៤៨,៨ពាន់តោន កើនឡើង៤%ធៀបនឹងខែមុននិងកើនឡើង១៦%ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ:

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:-១០% | (+៣%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:-៣៩% | (-៤០%) |
| ▪ កំពង់ផែកំពង់សោម:+៣០% | (+៤១%) | ▪ កំពង់ផែឧកញ៉ាម៉ុង: -៣៤% | (-១៤%) |

➢**ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍**

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន( ពាន់នាក់ ) | %∆ ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៩ | +៩% | +១៩% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៣៣,៤ | +២៤% | +៦៦% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៤៣១,៥ | +២១% | +១២% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៩៦,៧ | +៦% | +១៣% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៣៦៤,៣ | +១៤% | +៧% |
| ✓ តាមផ្លូវអាកាស | ១៩៣,៦ | +២៥% | +១៤% |
| ✓ តាមផ្លូវគោក និងទឹក | ១៧០,៧ | +៥% | 0% |

## ៥) ស្ថានភាពពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែកក្កដាមានចំនួន ៤៦០៥,២ពាន់លានរៀល (ស្មើនឹង ១១៥១,៣លានដុល្លារ ស.រ.អា.)កើនឡើង៨,៥%ធៀបនឹងខែមុន និងកើនឡើង៣១,៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ :

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -0,២% | +៣៨,៦% | រថយន្តសរុប (ព.ល.រ) | -១,៧% | +១២,៩% |
| ប្រេងម៉ាស៊ូត | -0,៩% | -៩,៤% | រថយន្តសរុប (គ្រឿង) | -៩,៥% | +១៩,៦% |
| ឧស្ម័ន | +២៧,៩% | +៧២% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +៩,២% | -៣៥,៥% |
| អគ្គិសនីនាំចូល | -៦៤,១% | -១,៤% | ម៉ូតូ (គ្រឿង) | -៦,៩% | +១២,៤% |
| ដែកសំណង់ | -១៥,២% | +១៧,៥% | អង្ករ | +0,៨% | +៣0២,២% |
| ស៊ីម៉ង់ត៍ | +១0,២% | +១៥,១% | ផ្លែឈើនិងបន្លែ | +២0,៦% | -៣១,៥% |
| គ្រឿងអេឡិចត្រូនិក | +២៣% | +៩៦,៣% | ជីនិងថ្នាំកសិកម្ម | -៣៣,៦% | -៣៤,១% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | -៧,៤% | +១0,៧% |

➡ **ការនាំចេញ** ខែកក្កដាឆ្នាំ២០១៥ មានចំនួន**៤០៩៩,៧**ពាន់លានរៀល ស្មើនឹង**១០២៤,៩**លានដុល្លារ ស.រ.អា. (៨៩% នៃការនាំចូល)កើនឡើង២០,៤%ធៀបនឹងខែមុនប៉ុន្តែកើនឡើង៣៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | -៣៤,៨% | -៣៨,៥% | ផលិតផលនេសាទ | +៧៥,២% | -៥៧,៥% |
| វាយនភណ្ឌនិងស្បែកជើង | +២៣,៥% | +៣៥,៧% | កៅស៊ូ | +១៣% | +២៥% |
| អង្ករ | -២០,៦% | +២១,៤% | | | |

➡ក្នុងខែកក្កដានេះជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ៥០៥,៥៣ពាន់លានរៀលស្មើនឹង១២៦,៤លានដុល្លារ ស.រ.អា.។

## ៦) ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែកក្កដាឆ្នាំ២០១៥នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃត្រីស្រស់ | +១,៧% | +៨,០% | — |
| ២ | ថ្លៃបន្លែ | +០,៩% | +៨,៣% | — |
| ៣ | អាករលើតម្លៃបន្ថែម | +២,១% | -១៥,០% | ក្នុងចំណូលពន្ធដារ |
| ៤ | ការនាំចូលអង្ករ | +០,៨% | +៣០២,២% | — |

## ៧) សេចក្ដីសន្និដ្ឋាន

១) ទោះបីជាទំនិញប្រើប្រាស់ជារួម មានសន្ទស្សន៍ថ្លៃកើនឡើងតែ ០.៨% ធៀបនឹងខែដូចគ្នាឆ្នាំមុនក៏ដោយ ប៉ុន្តែក្រុមម្ហូបអាហារ មានការឡើងថ្លៃខ្ពស់ (៣,៤%) ក្នុងនោះ គួរឲ្យកត់សម្គាល់បំផុតនោះគឺ ថ្លៃត្រីស្រស់ និងថ្លៃបន្លែ។

ការឡើងថ្លៃខ្ពស់នៃម្ហូបអាហារនឹងធ្វើឲ្យបន្ទុកចំណាយដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែធ្ងន់ធ្ងរ និងបើនិន្នាការនេះនៅតែបន្ត អាចជះឥទ្ធិពលលើការទាមទារតម្លើងប្រាក់ឈ្នួលពលកម្ម។

ជាទូទៅអតិផរណានៃក្រុមម្ហូបអាហារបណ្ដាលមកពីថ្លៃដើមខ្ពស់នៃវត្ថុធាតុដើមៈចំណីសត្វ ជីកសិកម្ម ឥន្ធនៈជាដើម ឬការឡើងថ្លៃនៃទំនិញនាំចូល។ ក្នុងពេលបច្ចុប្បន្ន ជាមួយនឹងការធ្លាក់ចុះនៃថ្លៃឥន្ធនៈជាសកល ការឡើងថ្លៃម្ហូបអាហារ ជាចម្បងអាចពន្យល់បានដោយសារតម្រូវការកើនលឿនជាងការផ្គត់ផ្គង់ និងការនាំចេញត្រីធម្មជាតិទៅទីផ្សារអន្តរជាតិ។

២) ការចិញ្ចឹមត្រីបែបវារីវប្បកម្មមានសក្ដានុពលយ៉ាងខ្លាំងនៅកម្ពុជាទាំងទឹកសាប ទាំងទឹកប្រៃ ដែលគួរតែពង្រីកដើម្បីអាចឆ្លើយតបនឹងតម្រូវការបាន។ ប៉ុន្តែ មានបញ្ហាប្រឈមមួយចំនួនដែលរារាំងកំណើនប្រកបដោយចីរភាពនៃវិស័យនេះ ដូចជា ខ្វះអតិបាលកិច្ច ការបណ្ដុះបណ្ដាល បច្ចេកទេស មជ្ឈមណ្ឌលស្រាវជ្រាវ ហិរញ្ញវត្ថុ និងទីផ្សារនាំចេញ។ បើមើលប្រទេសជិតខាង វៀតណាមក្នុងឆ្នាំ២០១៣ ធ្វើបានផលិតផល-វារីវប្បកម្ម ប្រមាណ៣,៣៤លានតោន (៥៥% នៃផលិតផលត្រីសរុប)និងនាំចេញទៅសហរដ្ឋអាមេរិក អឺរ៉ុប ជប៉ុន ចិន និងអាស៊ាន ដែលមានចំណូលសរុបប្រមាណជាង ៣ពាន់លានដុល្លារក្នុង១ឆ្នាំ (ប្រភពៈ *Directorate of Fisheries and General Statistics of Vietnam: http://www.seafood.vasep.com.vn/Daily-News/378_8877/Vietnam-fish-production-in-2013.htm*)។

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម ឃឹម ណុលឡា
# ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១៥

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៦/០៨/១៥<br>ម៉ោង០៩:០០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលរបស់សារមន្ទីរសព្វទស្សន៍អង្គរ (Angkor Panorama Museum) ដើម្បី ពិនិត្យ និងពិភាក្សាលើ៖<br>១-រៀបចំរចនាសម្ព័ន្ធសម្រាប់គ្រប់គ្រងសារមន្ទីរសព្វទស្សន៍អង្គរ។<br>២-កំណត់តម្លៃសំបុត្រ។<br>៣-បន្ថែមប្រព័ន្ធម៉ាស៊ីនបកប្រែដោយស្វ័យប្រវត្តិ និងគេហទំព័រ។<br>៤-ធ្វើវិសោធនកម្មនៃកិច្ចព្រមព្រៀងវិនិយោគសាងសង់សារមន្ទីរសព្វទស្សន៍អង្គរ។<br>៥-ការងារផ្សេងៗដែលទាក់ទងនឹងប្រតិបត្តិការសារមន្ទីរសព្វទស្សន៍អង្គរ។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ១០/០៨/១៥<br>ម៉ោង០៩:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ។<br>២-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ១១/០៨/១៥<br>ម៉ោង១០:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ។<br>២-បញ្ហាផ្សេងៗ។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ១៣/០៨/១៥<br>ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិតជ័យលាភី សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង សម្តេច កិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា
## ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច
## និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១៥ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៥ | ១៣/០៨/១៥<br>ម៉ោង១៥:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការសម្របសម្រួល និងសហការជាមួយភាគីចិនលើគម្រោងសាងសង់អគារ អង្គរក្សនៃទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យតម្លៃនៃកិច្ចសន្យាគូរប្លង់ និងតម្លៃប៉ាន់ស្មាននៃការងារសាងសង់អគារអង្គរក្សនៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលជាជំនួយឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ១៨/០៨/១៥<br>ម៉ោង១៥:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីគម្រោងវិនិយោគការសាងសង់អគារសារមន្ទីរសព្វទស្សន៍អង្គរ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ១៩/០៨/១៥<br>ម៉ោង០៩:១៥នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែង ក្នុងរចនាសម្ព័ន្ធគ្រប់ គ្រងនៃក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។<br>២-សេចក្តីព្រាងគោលនយោបាយដីធ្លី "សៀវភៅ ស ដីធ្លី"។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ២០/០៨/១៥<br>ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែកក្កដា ឆ្នាំ២០១៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ២១/០៨/១៥<br>ម៉ោង០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែង ក្នុងរចនាសម្ព័ន្ធគ្រប់ គ្រងនៃក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។<br>២-សេចក្តីព្រាងគោលនយោបាយដីធ្លី "សៀវភៅ ស ដីធ្លី"។ ***(លើក)***<br>៣-បញ្ហាផ្សេងៗ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១០ | ២២/០៨/១៥<br>ម៉ោង០៩:៣០នាទី | ចូលរួមជួបពិភាក្សាការងារជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅគេហដ្ឋាន ឯកឧត្តម បណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី។ |

## សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១៥ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១១ | **២២/០៨/១៥ ម៉ោង១៨:០០នាទី** | ចូលរួមទទួលទានអាហារសាមគ្គី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ១២ | **២៦/០៨/១៥ ម៉ោង០៧:៣០នាទី** | ចូលរួមជាសមាជិក ក្នុងពិធីប្រកាសផ្សព្វផ្សាយ និងដាក់ឲ្យអនុវត្ត " គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ " ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៣ | **២៦/០៨/១៥ ម៉ោង១៥:៣០នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ សេចក្តីព្រាងឯកសារយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨ ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | **២៧/០៨/១៥ ម៉ោង០៨:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | **២៧/០៨/១៥ ម៉ោង១៧:០០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយ តំណាងក្រុមហ៊ុន Union Development Group នៅបន្ទប់ឯកឧត្តម ប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | **២៨/០៨/១៥ ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងគោលនយោបាយដីធ្លី "សៀវភៅ ស ដីធ្លី"។<br>២-សេចក្តីព្រាងឯកសារយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨។<br>៣-បញ្ហាផ្សេងៗ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៧ | **៣១/០៨/១៥ ម៉ោង១៥:៣០នាទី** | ដឹកនាំគណៈកម្មការសម្របសម្រួល និងសហការជាមួយភាគីចិន ដើម្បីត្រួតពិនិត្យលើលទ្ធផលការងារសាងសង់អគារថ្មី នៅការដ្ឋានសាងសង់អគារថ្មីនៃទីស្តីការគណៈរដ្ឋមន្ត្រី។ |



រូបភាពក្នុងកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីទិវាជាតិអំណាន
នៅទីស្តីការគណៈរដ្ឋមន្ត្រី



# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in